ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០១០ គ.ជ.ប.ស.ណ.ន

# សេចក្តីណែនាំ
# ស្តីពី
# ការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ សេចក្តីសម្រេចលេខ ០៦៣/១៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងសេចក្តីសម្រេចលេខ ០០៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមធ្វើការណែនាំដល់លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) និងមេភូមិចាត់ចែងអនុវត្តការផ្តល់លិខិតអញ្ជើញជូនដល់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ដើម្បីបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ តាមខ្លឹមសារដូចខាងក្រោម៖

## I. គោលបំណង

គោលបំណងនៃការផ្តល់លិខិតអញ្ជើញនេះ គឺដើម្បីជម្រាបជូនដំណឹងដល់ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដូចខាងក្រោម ៖

- ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ហើយដែលបានប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលអស់សុពលភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតកន្លងមក ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងទៅធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោតតាមអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសុពលភាពក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦
- ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ហើយដែលបានប្រើ អ.ខ ដែលមានសុពលភាពក្នុងការចុះឈ្មោះបោះឆ្នោតកន្លងមក ដើម្បីពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យជីវប្រវត្តិ (ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត) របស់ខ្លួនក្នុងបញ្ជីបោះឆ្នោត ប្រសិនបើឃើញថាមានការកត់ត្រាមិនបានត្រឹមត្រូវតាម អ.ខ ដែលមានសុពលភាព សាមីខ្លួនអាចស្នើសុំកែតម្រូវក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦
- ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ដែលបានចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ ហើយមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពទិន្នន័យជីវប្រវត្តិក្នុងបញ្ជីបោះឆ្នោត

ពីមុនមក ដើម្បីទៅធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (ថតរូប និងផ្តិតម្រាមដៃ) ជាមួយក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦។

## II. ការអនុវត្តការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

### ១. ប្រធាន លធ.ខប ត្រូវចាត់ចែងបំពេញការងារដូចខាងក្រោម ៖

- ស្នើសុំកិច្ចសហការពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដើម្បីផ្តល់ការគាំទ្រចំពោះ កបឃ.ស និងចាត់ចែងផ្សព្វផ្សាយសេចក្តីណែនាំនេះដល់ កបឃ.ស មេភូមិ តំណាងគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សំដៅឈានទៅអនុវត្តការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតតាមឈ្មោះ និងទិន្នន័យដែលមាននៅក្នុងលិខិតអញ្ជើញក្នុងឃុំ សង្កាត់ពាក់ព័ន្ធឱ្យបានដល់សាមីខ្លួនគ្រប់ៗគ្នា
- ប្រគល់កញ្ចប់លិខិតអញ្ជើញនៃឃុំ សង្កាត់ជូនទៅ កបឃ.ស ពាក់ព័ន្ធដែលមានភារកិច្ចទទួលខុសត្រូវក្នុងការផ្តល់លិខិតអញ្ជើញជូនដល់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងត្រូវណែនាំ កបឃ.ស អំពីដំណើរការផ្តល់លិខិតអញ្ជើញនេះក្នុងឃុំ សង្កាត់របស់ខ្លួន
- ជូនព័ត៌មាន និងអញ្ជើញតំណាងគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងចូលរួមសង្កេតមើលការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- តាមដានត្រួតពិនិត្យរាល់សកម្មភាពរបស់ កបឃ.ស ក្នុងការផ្តល់លិខិតអញ្ជើញ និងជួយសម្រួលដោះស្រាយរាល់បញ្ហាដែលអាចកើតមានជាយថាហេតុ
- ផ្តល់របាយការណ៍ប្រចាំសប្តាហ៍ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប អំពីសកម្មភាពនៃការផ្តល់លិខិតអញ្ជើញ និងហេតុការណ៍កើតឡើងដែលត្រូវស្នើសុំអន្តរាគមន៍ដោះស្រាយ។

### ២. ប្រធាន កបឃ.ស ត្រូវបំពេញការងារដូចខាងក្រោម ៖

- កំណត់ប្រតិទិនសម្រាប់ការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៅតាមភូមិនានាក្នុងឃុំ សង្កាត់ ស្របតាមប្រតិទិនដែលបានកំណត់ដោយ គ.ជ.ប
- ប្រជុំជាមួយមេភូមិ តំណាងគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយអំពីគោលបំណង សារប្រយោជន៍ និងការអនុវត្តការផ្តល់លិខិតអញ្ជើញព្រមទាំងបន្តការផ្សព្វផ្សាយអំពីខ្លឹមសារទាំងនេះជូនប្រជាពលរដ្ឋ
- ប្រគល់លិខិតអញ្ជើញជូនមេភូមិ ដោយផ្អែកទៅតាមចំនួនឈ្មោះ ទិន្នន័យ និងអាសយដ្ឋានរបស់ប្រជាពលរដ្ឋនៅក្នុងភូមិពាក់ព័ន្ធ
- ណែនាំមេភូមិឱ្យយកចិត្តទុកដាក់ពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងលិខិតអញ្ជើញជាមួយនឹង អ.ខ របស់សាមីខ្លួន មុននឹងប្រគល់ជូនសាមីខ្លួន
- ប្រគល់ភារកិច្ចជូនសមាជិក កបឃ.ស ម្នាក់ៗឱ្យទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានរាល់សកម្មភាពរបស់មេភូមិក្នុងការផ្តល់លិខិតអញ្ជើញ និងជួយសម្រួលដោះស្រាយរាល់បញ្ហាដែលអាចកើតមានឡើងជាយថាហេតុក្នុងឃុំ សង្កាត់របស់ខ្លួន

- ជូនព័ត៌មាន និងអញ្ជើញតំណាងគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងចង់ចូលរួមសង្កេតមើលការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- ផ្តល់របាយការណ៍ប្រចាំសប្តាហ៍ជូន លធ.ខប អំពីសកម្មភាពនៃការផ្តល់លិខិតអញ្ជើញ និងហេតុការណ៍ណាមួយកើតឡើងដែលនឹងត្រូវស្នើសុំដោះស្រាយ
- ប្រជុំពិនិត្យសម្រេចលើរបាយការណ៍លទ្ធផលនៃការផ្តល់លិខិតអញ្ជើញនៅពេលបញ្ចប់ការងារ និងរាយការណ៍ជូន គ.ជ.ប តាមរយៈ លធ.ខប
- ក្រោយបញ្ចប់រយៈពេលនៃការផ្តល់លិខិតអញ្ជើញប្រសិនបើមានលិខិតអញ្ជើញនៅសល់ត្រូវរក្សាទុកនៅសាលាឃុំ សង្កាត់ ដើម្បីបន្តផ្តល់ជូនអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលមិនទាន់បានទទួលរហូតដល់ថ្ងៃបញ្ចប់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦។

៣. **មេភូមិត្រូវបំពេញការងារដូចខាងក្រោម ៖**

- ប្រជុំជាមួយប្រជាពលរដ្ឋក្នុងភូមិ ដើម្បីផ្សព្វផ្សាយអំពីគោលបំណង និងសារៈសំខាន់នៃការផ្តល់លិខិតអញ្ជើញនេះ
- យកចិត្តទុកដាក់ពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងលិខិតអញ្ជើញជាមួយនឹង អ.ខ របស់សាមីខ្លួនមុននឹងប្រគល់ជូនសាមីខ្លួន
- ផ្តល់លិខិតអញ្ជើញជូនប្រជាពលរដ្ឋ ដោយផ្អែកតាមឈ្មោះ និងទិន្នន័យពាក់ព័ន្ធដែលមាននៅក្នុងលិខិតអញ្ជើញនេះ រួចជម្រាបគាត់ឱ្យពិនិត្យបន្ថែមលើឈ្មោះ និងទិន្នន័យរបស់ខ្លួន និងខ្លឹមសារសំខាន់ៗ ដែលមាននៅផ្នែកខាងមុខនៃលិខិតអញ្ជើញ ព្រមទាំងសេចក្តីបញ្ជាក់នៅខាងខ្នងលិខិតអញ្ជើញ
- ចុះតាមលំនៅឋាន ឬទីសំណាក់ប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន ដោយមានការចូលរួមពីជំនួយការភូមិ ដើម្បីផ្តល់លិខិតអញ្ជើញនេះជូនតាមក្រុមគ្រួសារ
- ផ្តល់ព័ត៌មានលម្អិតជូនប្រជាពលរដ្ឋ បើទោះបីជាមិនបានទទួលលិខិតអញ្ជើញនេះក៏អាចទៅធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតបានដែរ
- ក្រោយបញ្ចប់រយៈពេលនៃការផ្តល់លិខិតអញ្ជើញត្រូវបញ្ជូនលិខិតអញ្ជើញដែលនៅសល់ទៅរក្សាទុកនៅសាលាឃុំ សង្កាត់ ដើម្បីបន្តផ្តល់ជូនប្រជាពលរដ្ឋដែលមិនទាន់បានទទួលរហូតដល់ថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការផ្តល់លិខិតអញ្ជើញដល់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងភូមិរបស់ខ្លួនជូនទៅ កបឃ.ស។

## III. ប្រតិទិននៃការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

ការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ត្រូវអនុវត្តតាមប្រតិទិនដូចមានជូនភ្ជាប់មកជាមួយ។ ការផ្តល់លិខិតអញ្ជើញនៅតាមភូមិចាប់ផ្តើមពីថ្ងៃទី៧ ខែកញ្ញា ដល់ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៦។

## IV. ការត្រួតពិនិត្យលទ្ធផលនៃការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

១- លធ.ខប ត្រូវពិនិត្យវាយតម្លៃលទ្ធផលនៃការផ្តល់លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងបូកសរុបរបាយការណ៍ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប។ ក្នុងនោះដែរ លធ.ខប ត្រូវយកចិត្តទុកដាក់ដូចជា ៖

- ត្រួតពិនិត្យចំនួនលិខិតអញ្ជើញដែលនៅសល់ដើម្បីរក្សាទុកនៅតាមឃុំ សង្កាត់នីមួយៗ
- ចុះសាកសួរប្រជាពលរដ្ឋមួយចំនួនដោយផ្ទាល់នៅតាមផ្ទះក្នុងភូមិមួយចំនួនក្នុងឃុំ សង្កាត់ ដើម្បីប៉ាន់ស្មានភាគរយនៃប្រជាពលរដ្ឋដែលបានទទួលលិខិតអញ្ជើញ
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការផ្តល់លិខិតអញ្ជើញក្នុងរាជធានី ខេត្តរបស់ខ្លួនជូន គ.ជ.ប។

២- អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវបូកសរុបលទ្ធផលនៃការផ្តល់លិខិតអញ្ជើញទាំង ២៥ រាជធានី ខេត្ត ដើម្បីរាយការណ៍ជូន គ.ជ.ប។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការ គ.ជ.ប ប្រធាន លធ.ខប ប្រធាន កបឃ.ស និងមេភូមិ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព។

ថ្ងៃសុក្រ ៧រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែឧសភា ឆ្នាំ២០២៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

**ប្រាជ្ញ ចន្ទ**

**ចម្លងជូន ៖**
- ក្រសួងមហាផ្ទៃ
- គណបក្សនយោបាយ
- ឯកសារ កាលប្បវត្តិ